# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Dec-2014, 11:20
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## ពាក្យសុំរបស់ មាស មុត សុំឱ្យអង្គបុរេជំនុំជម្រះឱ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកាកោះឱ្យបង្ហាញខ្លួនបឋម

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាងឧត្តម

Michael G. KARNAVAS

**ចម្លងជូន៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមតាមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. (“វិធាន”) តាមរយៈនេះ ស្នើសហចៅក្រមស៊ើបអង្កេតឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះឲ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំឲ្យទុកជាមោឃៈនូវ *ដីកាកោះឲ្យបង្ហាញខ្លួនបឋម* នេះ[1]។ ពាក្យសុំនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះ ដីកាកោះគឺមិនមានសុពលភាព៖ ដីកានេះគួរត្រូវបានចេញរួមគ្នាដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប ប៉ុន្តែ បែរជាត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេត Harmon តែម្នាក់ឯង។ កំហុសនីតិវិធីនេះធ្វើឲ្យខូចប្រយោជន៍ដល់លោក មាស មុត ពីព្រោះសហចៅក្រមស៊ើបអង្កេត Harmon ចាត់ទុកថា លោក មាស មុត បានរំលោភបំពានលើដីកាដែលចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ទោះបីជាគាត់មិនបានរំលោភបំពានក៏ដោយ។ សហចៅក្រមស៊ើបអង្កេត Harmon មានបំណងចង់ពិចារណាលើវិធានការណ៍ដើម្បីបង្ខិតបង្ខំលោក មាស មុត ឲ្យអនុវត្តតាមដីកាកោះដែលមានកំហុសនីតិវិធីនេះ។ មេធាវីការពារក្តីស្នើសុំដាក់ពាក្យសុំនេះជាភាសាអង់គ្លេសសិន ហើយឯកសារបកប្រែជាភាសាខ្មែរនឹងត្រូវបានដាក់តាមក្រោយ ដោយហេតុថា អង្គភាពបកប្រែភាសាមិនអាចធ្វើការបកប្រែចប់ទាន់ពេលវេលា[2]។

## I. សាវតារ

១. នៅថ្ងៃទី ០៧ និង ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ និង នៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតបានដាក់ការខ្វែងយោបល់គ្នា។ មេធាវីការពារក្តីមិនបានដឹងអំពីលក្ខណៈនៃការខ្វែងយោបល់គ្នានេះឡើយ ប៉ុន្តែសហចៅក្រមស៊ើបអង្កេត Harmon បានជម្រាបមកមេធាវីការពារក្តីថា យ៉ាងហោចណាស់ ការខ្វែងយោបល់គ្នាចំនួនពីរ នៅលើកទីមួយនោះ មិនត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង ស្តីពីនីតិវិធីនៃការដោះស្រាយជម្លោះឡើយ[3]។

---

[1] ដីកាកោះឲ្យបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66។

[2] *សូមមើល* សារអេឡិចត្រូនិចរបស់អង្គភាពបកប្រែភាសា ផ្ញើមកកាន់មេធាវីការពារក្តី “កម្មវត្ថុ៖ សំណើសុំបកប្រែ” ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤។

[3] *សូមមើល* លិខិតរបស់សហចៅក្រមស៊ើបអង្កេត Harmon ផ្ញើរទៅមេធាវីការពារក្តី *សំណើសុំព័ត៌មានទាក់ទងនឹងកំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ និង ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៣* ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D82/3/2។

២. នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ វិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរ បានរាយការណ៍ថា ជនសង្ស័យមួយរូបនៅក្នុងរឿងក្តី ០០៤ ត្រូវបានកោះហៅដោយ អ.វ.ត.ក.[4]។

៣. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានផ្ញើលិខិតមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំសំអាងហេតុផ្លូវច្បាប់ពីសហចៅក្រមស៊ើបអង្កេតម្នាក់ៗ ទាក់ទងនឹងបញ្ហាថា តើដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ឯង នឹងមានសុពលភាព ដែរឬយ៉ាងណា។ មេធាវីការពារក្តីបានកត់សម្គាល់ថា៖

ក. សហចៅក្រមស៊ើបអង្កេតបានដាក់ការខ្វែងយោបល់គ្នាចំនួនពីរ (នៅពេលនោះ មេធាវីការពារក្តីមិនបានដឹងថាមានការខ្វែងយោបល់គ្នាលើកទីបីត្រូវបានធ្វើកំណត់ហេតុនោះទេ) គឺចៅក្រម យូ ប៊ុនឡេង បានបញ្ជូនសំណុំរឿងរួចរាល់ហើយទៅសហព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ ហើយសហចៅក្រមស៊ើបអង្កេតមិនបានបំពេញការងារជាមួយគ្នាលើសេចក្តីសម្រេច ដីកាសម្រេច ឬ ឯកសារឆ្លើយឆ្លងដែលចេញនៅក្នុងរឿងក្តី ០០៣ ឡើយ (តាមដែលមេធាវីការពារក្តីបានដឹង) ចាប់តាំងពីពេលនោះមក។

ខ. ប្រសិនបើសហចៅក្រមស៊ើបអង្កេត Harmon សម្រេចកោះហៅលោក មាស មុត ជាឯកតោភាគីនោះ មេធាវីការពារក្តីនឹងទាមទារនូវសំអាងហេតុផ្លូវច្បាប់របស់សហចៅក្រមស៊ើបអង្កេត *ម្នាក់ៗ* ទាក់ទងសុពលភាពនៃដីកាកោះ ដើម្បីផ្តល់ប្រឹក្សាដល់លោក មាស មុត ប្រកបដោយអត្ថន័យ។

គ. សុពលភាពនៃដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ មិនត្រូវបានលើកឡើងឲ្យបានច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឬ វិធានផ្ទៃក្នុងឡើយ។

ឃ. នៅក្នុងស្ថានភាពកន្លងមក ពេលដែលសហចៅក្រមស៊ើបអង្កេតខ្វែងយោបល់គ្នា សកម្មភាពរបស់សហចៅក្រមស៊ើបអង្កេតមួយរូប ត្រូវចាត់ទុកថាមានសុពលភាព ប៉ុន្តែ ស្ថានភាពពេលនោះមានភាពខុសគ្នា ព្រោះពាក់ព័ន្ធជាមួយដីកាកោះហៅសាក្សី ដែលជាប់ពាក់ព័ន្ធទៅនឹងការបន្តកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ (មិនដូចទៅនឹងដីកាកោះជនសង្ស័យឡើយ)។

---

[4] *សូមមើល* សុខ ខេមរា *ជនសង្ស័យខ្មែរក្រហមបន្ថែមទៀត ដែលត្រូវបង្ហាញខ្លួននៅអង្គជំនុំជម្រះ នៅថ្ងៃច័ន្ទ វិទ្យុសហរដ្ឋអាមេរិកជាភាសាខ្មែរ ផ្សាយនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ អាចរកបាននៅ* http://www.voacambodia.com/content/additional-khmer-rouge-suspect-to-appear-at-tribunal-monday/2409141.html.

ង. ការកោះហៅលោក មាស មុត ក្នុងគោលបំណងចោទប្រកាន់គាត់ *មិន* ទាក់ទងថាតើការស៊ើបអង្កេតនឹងបន្ត ឬអត់នោះឡើយ ហើយក៏មិនអាចចាត់ទុកថាជាសកម្មភាពស៊ើបអង្កេតបានដែរ[5]។

៤. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចមួយក្នុងរឿងក្តី ០០៤ ដោយសម្រេចទៅលើសុពលភាពនៃដីកាកោះហៅជនសង្ស័យម្នាក់ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែមួយរូប ដែលបំពេញការងារតែម្នាក់ឯង (“សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុងរឿងក្តី ០០៤”)។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតបានចុះបញ្ជីការខ្វែងយោបល់គ្នាទាក់ទងនឹងដីកាកោះ ហើយថា រយៈពេល ៣០ ថ្ងៃក្នុងការបញ្ជូនការខ្វែងយោបល់គ្នាមកអង្គបុរេជំនុំជម្រះ បានកន្លងផុតហើយ ហើយ៖

> នៅក្នុងកាលៈទេសៈទាំងនេះ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា បង្កើតឲ្យមាន អ.វ.ត.ក. ច្បាប់ អ.វ.ត.ក. និង វិធានផ្ទៃក្នុង បានបង្ហាញយ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិអាចចេញដីកាកោះដោយមានសុពលភាពតែម្នាក់ឯងបាន។ ម៉្យាងវិញទៀត អង្គបុរេជំនុំជម្រះបានបញ្ជាក់នាពេលមុនរួចមកហើយថា សហព្រះរាជអាជ្ញាម្នាក់ ឬ សហចៅក្រមស៊ើបអង្កេតម្នាក់អាចបំពេញកិច្ចតែម្នាក់ឯងបាន នៅពេលការខ្វែងយោបល់គ្នាបានចុះបញ្ជីរួចរាល់ នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ឬ ការិយាល័យសហចៅក្រមស៊ើបអង្កេត តាមករណីសមស្រប និង រយៈពេលនាំយកការខ្វែងយោបល់គ្នា មកចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុត។ វាជាការមិនសមស្របឡើយ ប្រសិនបើ អង្គបុរេជំនុំជម្រះពិចារណាព្យួរការអនុវត្តដីកាកោះ ដោយផ្អែកលើពាក្យសុំនាពេលចុងក្រោយ ដែលទំនងជានឹងធ្វើការតវ៉ាលើវិធានមួយដែលចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិនៃកម្រងច្បាប់ អ.វ.ត.ក. និង យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ[6]។

---

[5] លិខិតរបស់មេធាវីការពារក្តី សំណុំរឿង ០០៣ ផ្ញើរជូន ក.ស.ច.ស. *សំណើសុំព័ត៌មានទាក់ទងនឹងសុពលភាពដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ [ទទួលបានការជូនដំណឹងនៅថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៤] ឯកសារ D117។

[6] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៩) សេចក្តីសម្រេចលើ [redacted] សំណើបន្ទាន់ [redacted] ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/3 កថាខណ្ឌ ១៤ (លេខឯកសារក្នុងសំណុំរឿង ០០៣ គឺ D117/1.2)។

៥. នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត Harmon បានចេញដីកាសម្រេចថា "សុពលភាពនៃដីកាកោះហៅជនសង្ស័យណាម្នាក់ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ គឺមានចែងយ៉ាងច្បាស់ នៅក្នុងច្បាប់ជាធរមាន ជាពិសេសនៅក្នុងមាត្រា ៥ និង ៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក. មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង វិធាន ៧២ នៃវិធានផ្ទៃក្នុង"[7]។ លោកបានច្រានចោលសារណារបស់មេធាវីការពារក្តី ដែលថា ការកោះហៅជនសង្ស័យម្នាក់ មិនមែនជាសកម្មភាពស៊ើបអង្កេតទេ ហើយបានពន្យល់ថា វិធាន ៧២ អនុវត្តបានចំពោះ *គ្រប់* សកម្មភាពទាំងអស់ ដែលសហចៅក្រមស៊ើបអង្កេតបានបំពេញក្នុងអំឡុងពេលស៊ើបអង្កេត។ គាត់បានយោងសេចក្តីសម្រេចកោសលុបរបស់អង្គបុរេជំនុំជម្រះក្នុងរឿងក្តី ០០៤។ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង មិនបានចេញដីកានេះរួមគ្នាជាមួយសហចៅក្រមស៊ើបអង្កេត Harmon ឬក៏ផ្តល់សំអាងហេតុផ្លូវច្បាប់ទាក់ទងនឹងសុពលភាពនៃដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែមួយរូបឡើយ។

៦. នៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ដីកានេះ។ មេធាវីការពារក្តីបានអះអាង*នៅក្នុងចំណោមនោះ* ថា សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការជាមួយគ្នា និង ចេញដីកាកោះរួមគ្នា ហើយថា កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មិនបានចែងអំពីដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតមួយរូប តែម្នាក់ឯង នៅក្នុងករណីខ្វែងយោបល់គ្នាឡើយ ព្រមទាំងថា វិធាន ៧២ មិនអាចត្រូវបានពឹងផ្អែក ដើម្បីអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតមួយរូបចេញដីកាកោះតែម្នាក់ឯងនោះឡើយ[8]។

៧. នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត Harmon បានកោះហៅលោក មាស មុត និង សហមេធាវីរបស់គាត់ឲ្យបង្ហាញខ្លួនបឋមដែលគ្រោងធ្វើនៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ

---

[7] ដីកាសម្រេចលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែមួយរូប ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៤ ឯកសារ D117/1 កថាខណ្ឌ ៣។

[8] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្តីពីសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតមួយរូប ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៤ D117/1/1/1។

២០១៥[9]។ ដីកាកោះហៅលោក មាស មុត បានថ្លែងថា៖ "ប្រសិនបើ មាស មុត មិនមកបង្ហាញខ្លួនតាមកាលបរិច្ឆេទដូចបានបញ្ជាក់ខាងលើទេ វិធានការណ៍បន្ថែមទៀតដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. នឹងត្រូវយកមកពិចារណា"[10]។

៨. នៅថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៤ មេធាវីការពារក្តីបានជួបជាមួយនឹងលោក មាស មុត ដើម្បីពិភាក្សាអំពីដីកាកោះ។ លោក មាស មុត បានចង្អុលបង្ហាញថា គាត់មិនបានចាត់ទុកថា ដីកាកោះមានសុពលភាពនោះឡើយ ដោយសារតែដីកានេះត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេត Harmon តែម្នាក់ឯង។ មេធាវីការពារក្តីបានរៀបចំសេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះដោយសារមូលហេតុនេះ ដែលលោក មាស មុត បានចុះហត្ថលេខា[11]។ សេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះនេះ ត្រូវបានដាក់នៅថ្ងៃបន្ទាប់ គឺថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤។ លោក មាស មុត បានថ្លែង *នៅក្នុងចំណោមនោះ* ថា៖

> ដីកាកោះនេះត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេត Harmon។ ហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង មិនមាននៅលើដីកាកោះនោះទេ។ ដូច្នេះ ខ្ញុំបាទមិនចាត់ទុកដីកាកោះថាមានសុពលភាព ដែលចេញពីសហចៅក្រមស៊ើបអង្កេតទាំងពីរនាក់ឡើយ ... សហមេធាវីរបស់ខ្ញុំបាទ បានជូនដំណឹងដល់ខ្ញុំបាទថា លោក សហចៅក្រមស៊ើបអង្កេត Harmon នាពេលថ្មីៗនេះបានសម្រេចដោយខ្លួនលោកផ្ទាល់ និង ដោយគ្មានសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង លើកពេលម្តងហើយម្តងទៀតក្នុងការចេញសេចក្តីសម្រេចថា តើលោកនឹងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីរបស់ខ្ញុំបាទចូលពិនិត្យមើលសំណុំរឿងឬយ៉ាងណា ... វាហាក់ដូចជាបង្ហាញថា គោលជំហររបស់លោកគឺថា ដើម្បីលៃលកឲ្យខ្ញុំបាទអាចចូលពិនិត្យមើលសំណុំរឿង សម្រាប់ឲ្យខ្ញុំបាទអាចអនុវត្តសិទ្ធិរបស់ខ្ញុំបាទយ៉ាងពេញលេញក្នុងការការពារក្តី និង សិទ្ធិរបស់ខ្ញុំបាទក្នុងការជួយដល់កិច្ចការពារក្តីរបស់ខ្ញុំបាទផ្ទាល់

---

[9] ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសេវាបញ្ជូនដីកាកោះ ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A66/1។ ដីកាកោះហៅមេធាវី ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A67។

[10] ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66។

[11] *សូមមើល* សេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1។ សេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1.1។

ខ្ញុំបាទត្រូវតែអនុវត្តតាមដីកាកោះរបស់លោក។ លក្ខខណ្ឌដោះដូរ (Quid pro quo) នេះគឺជាការប្រមាថ។ ការអនុវត្តតាមដីកាកោះ ដែលគ្មានសុពលភាពមិនអាចធ្វើទៅបានក្នុងលក្ខខណ្ឌកំណត់ជាមុន អំពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់ខ្ញុំបាទឡើយ។ ក្រុមមេធាវីការពារក្ដីរបស់ខ្ញុំបាទត្រូវតែបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង និង ចូលរួមនៅក្នុងកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការជាបន្ទាន់។ នេះគឺជាប្រភេទនៃចរិយាដែលត្រូវបានរំពឹងទុក ជាមុនពីសំណាក់រដ្ឋអាជ្ញាមកពីប្រព័ន្ធច្បាប់តទល់ (adversarial legal system) មិនមែនមកពីចៅក្រមឡើយ ទោះបីជាប្រព័ន្ធអ្វីក៏ដោយ[12]។

៩. នៅថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានសម្រេចថា បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី គឺមិនអាចទទួលយកបាន នៅលើមូលដ្ឋានដែលថា គ្មានផលអាក្រក់ដែលធ្វើឲ្យមានព្យសនកម្មមិនអាចជួសជុលបានដល់សិទ្ធិសច្ចភាពគតិយុត្តិរបស់លោក មាស មុត ឡើយ ហើយដោយហេតុថា អង្គបុរេជំនុំជម្រះ ពុំមានយុត្តាធិការដើម្បីដោះស្រាយបញ្ហាជាសម្មតិកម្ម ឬ ផ្ដល់នូវមតិយោបល់ណែនាំនោះទេ[13]។

១០. នៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត Harmon បានចេញលិខិតមួយច្បាប់ដែលថ្លែងថា គាត់បានទទួលសេចក្ដីជូនដំណឹងរបស់លោក មាស មុត ស្ដីពីការមិនទទួលស្គាល់ដីកាកោះហើយ។ សហចៅក្រមស៊ើបអង្កេត Harmon បានថ្លែងថា គាត់បានចាត់ទុកថា ដីកាកោះមានសុពលភាព ហើយ៖ "ដូច្នេះ យើងរំពឹងថា ជនសង្ស័យនឹងចូលបង្ហាញខ្លួនបឋមដូចដែលបានគ្រោងទុកនៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៤។ ការមិនមកបង្ហាញខ្លួន គឺជាការរំលោភបំពានដោយផ្ទាល់ទៅលើដីកាដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់។ នៅក្នុងករណីនោះ យើងនឹងចាត់វិធានការណ៍បន្ថែមទៀតដែលមាននៅក្នុងច្បាប់ជាធរមានរបស់ អ.វ.ត.ក. ដើម្បីធានាឲ្យមានការបង្ហាញខ្លួននេះ"[14]។ សហ

[12] សេចក្ដីជូនដំណឹងស្ដីពីការមិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1.1 (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[13] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D117/1/1/2 កថាខណ្ឌ ១៥-១៦។

[14] ចម្លើយតបទៅនឹងសេចក្ដីជូនដំណឹងស្ដីពីសេចក្ដីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ ("លិខិត") ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1/1 (ដកស្រង់ពីកថាខណ្ឌ ៥)។

ចៅក្រមស៊ើបអង្កេត Harmon ក៏បានចង្អុលបង្ហាញផងដែរ ថាសហមេធាវីត្រូវបានរំពឹងទុកថា បង្ហាញខ្លួននៅឯការបង្ហាញខ្លួនបឋម[15]។

១១. នៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៤ សហមេធាវីជាតិ អាង ឧត្តម អ្នកប្រឹក្សាច្បាប់ជាន់ខ្ពស់ Tanya Pettay និង អ្នកគ្រប់គ្រងសំណុំរឿង ម៉ាង ម៉ូនីកា បានបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត Harmon[16]។ លោក មាស មុត មិនមានវត្តមាននោះទេ។ សហចៅក្រមស៊ើបអង្កេត Harmon បានចោទសួរថា តើមេធាវីការពារក្តីបានទទួលលិខិតរបស់គាត់ដែលពន្យល់ថា គាត់ សហចៅក្រមស៊ើបអង្កេត Harmon បានចាត់ទុកថា ដីកាកោះមានសុពលភាព ដែរឬទេ។ លោក អាង ឧត្តម បានថ្លែងថា មេធាវីការពារក្តីបានទទួលលិខិតនោះ។ សហចៅក្រមស៊ើបអង្កេត Harmon បានសួរថា ថ្វីបើមានលិខិត តើវាគឺជាជម្រើសរបស់លោក មាស មុត ក្នុងការមិនបង្ហាញខ្លួន ឬយ៉ាងណា ដែលលោក អាង ឧត្តមបានពន្យល់តបថា វាគឺជាជម្រើសរបស់លោក មាស មុត។ បន្ទាប់មក លោក អាង ឧត្តមបានស្នើសុំចូលពិនិត្យមើលសំណុំរឿង និង បានស្នើសុំព័ត៌មានអំពីថាតើហេតុអ្វីបានជាសហចៅក្រមស៊ើបអង្កេតជាតិមិនមានវត្តមាន។ សហចៅក្រមស៊ើបអង្កេត Harmon បានបដិសេធសំណើសុំចូលពិនិត្យមើលសំណុំរឿង និង បានថ្លែងថា មូលហេតុដែលសហចៅក្រមស៊ើបអង្កេតជាតិមិនមានវត្តមាន គឺជាការសម្ងាត់។ បន្ទាប់មក សវនាការនៃការបង្ហាញខ្លួនបឋម ត្រូវបានផ្អាក[17]។

---

[15] *ដូចខាងលើ* កថាខណ្ឌ ៦។

[16] *សូមមើល* សេចក្តីជូនដំណឹងទាក់ទងនឹងការចូលរួមនៅក្នុងការបង្ហាញខ្លួនបឋមដែលគ្រោងធ្វើនៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៤ ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/2 ដែលក្នុងនោះសហមេធាវីអន្តរជាតិ Michael G. Karnavas បានស្នើថា អ្នកប្រឹក្សាច្បាប់ជាន់ខ្ពស់ Tanya Pettay បង្ហាញខ្លួនជំនួសគាត់ ដោយសារមានកិច្ចការដទៃទៀតដែលបានគ្រោងធ្វើពីមុនរួចមកហើយ និង ចម្លើយតបទៅនឹងសេចក្តីជូនដំណឹងទាក់ទងនឹងការចូលរួមការបង្ហាញខ្លួនបឋមដែលគ្រោងធ្វើនៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៤ ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៤ ("សេចក្តីជូនដំណឹង") ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/2/1 ដែលក្នុងនោះសហចៅក្រមស៊ើបអង្កេត Harmon បានអនុញ្ញាតតាមសំណើនេះ។

[17] *សូមមើល* កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការបង្ហាញខ្លួនបឋម ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ D122។

## II. ច្បាប់ជាធរមាន

### ក. ពាក្យសុំមោឃភាព

១២. វិធាន ៤៨ ចែងថា៖ "កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ"។

១៣. វិធាន ៧៦(២) ចែងថា៖

ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ប្ដឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកា ដែលអាចជាការទទួលយក ឬ បដិសេធសំណើសុំភ្លាមៗតាមតែអាចធ្វើទៅបាន និង ក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ ដីកាបែបនេះ គឺជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ។

### ខ. កាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើការជាមួយគ្នា និង ដំណើរការនៃការដោះស្រាយជម្លោះ

១៤. មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្ដីពីការបង្កើត អ.វ.ត.ក. ចែងថា៖

សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុង ករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះ ត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧។

១៥. មាត្រា ២៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ចែងថា៖

រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ... ក្នុងករណីដែលមានភាពមិនយល់ស្របគ្នា រវាងសហចៅក្រម ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖

ការស៊ើបអង្កេតត្រូវធ្វើបន្ត ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬ មួយរូប ក្នុងចំណោមពួកគេពុំបានប្ដឹងមិនសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃ ថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម។

១៦. វិធាន ៧២(២) និង៧២(៣) ចែងថា៖

២. ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ សហចៅក្រមស៊ើបអង្កេតណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះដោយបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និង មូលហេតុនៃការខ្វែងយោបល់គ្នានេះ ទៅការិយាល័យរដ្ឋបាល ដែលត្រូវរៀបចំកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ និងបញ្ជូនឯកសារទាំងនេះទៅចៅក្រមទាំងអស់ ដោយចម្លងជូនមួយច្បាប់ទៅសហចៅក្រមស៊ើបអង្កេតម្ខាងទៀត។ ប្រសិនបើការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ រយៈពេលនេះត្រូវបន្ថយ មកត្រឹម ៥(ប្រាំ)ថ្ងៃ វិញ។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតម្ខាងទៀត អាចដាក់ជូនឯកសារឆ្លើយតបក្នុង រយៈពេល ១០ (ដប់) ថ្ងៃ។ ឯកសារអំណះអំណាងដែលទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ លើកលែងតែក្នុងករណីដែលមានចែងក្នុងអនុវិធាន ៤ (ខ) ខាងក្រោម។ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងថតចម្លងមួយច្បាប់ទៅអង្គបុរេជំនុំជម្រះភ្លាម។

៣. ក្នុងអំឡុងពេលនៃការដោះស្រាយការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវប្រឹងប្រែងស្វែងរកការឯកភាពគ្នា។ កិច្ច ឬ សេចក្ដីសម្រេចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានេះត្រូវតែអនុវត្ត លើកលែងតែបញ្ហាខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម ៖

ក-សេចក្ដីសម្រេចណាមួយដែលអាចនាំឲ្យជនត្រូវចោទ ឬ ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើបណ្ដឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ។

ខ-ការជូនដំណឹងអំពីបទចោទប្រកាន់ ។ ឬ

គ-ដីកាបង្គាប់ឲ្យចាប់ខ្លួន។

ក្នុងករណីទាំងនេះ គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅការខ្វែងយោបល់គ្នា ត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានបង្កើតឡើង ឬ រយៈពេល ៣០

(សាមសិប) ថ្ងៃ បានកន្លងហួស ឬ អង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ។

## III. បទដ្ឋាននៃការត្រួតពិនិត្យឡើងវិញលើពាក្យសុំមោឃភាព

១៧. អង្គបុរេជំនុំជម្រះនៅក្នុងរឿងក្តី ០០២ បានសម្រេចថា៖

វិធាន ៧៦(២) នៃវិធានផ្ទៃក្នុង ចែងឲ្យសហចៅក្រមស៊ើបអង្កេតពិចារណាលើ "សំណើ" ដើម្បីប្តឹងទៅអង្គជំនុំជម្រះអំពីពាក្យសុំមោឃភាព។ អនុវិធានមិនបានចែងឲ្យសហចៅក្រមស៊ើបអង្កេតសម្រេច អំពីភាពសមនឹងទទួលរបស់ពាក្យសុំឡើយ នេះគឺជាតួនាទីរបស់អង្គបុរេជំនុំជម្រះ ដែលត្រូវបានចែងយ៉ាងច្បាស់ដោយវិធាន ៧៣(ខ) នៃវិធានផ្ទៃក្នុង[18]។

១៨. អង្គបុរេជំនុំជម្រះបានពន្យល់បន្ថែមទៀតថា៖

នៅពេលដែលពិចារណាលើពាក្យសុំក្នុងវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវពិនិត្យជាផ្លូវការត្រឹមតែថា តើមានពាក្យសុំដែលគាំទ្រដោយអំណះអំណាងដែលមានសំអាងហេតុ ដែលធ្វើការអះអាងថាមានកំហុសនីតិវិធី ហើយកំហុសនោះធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទាំងឡាយរបស់ភាគីក្នុងការធ្វើពាក្យសុំ ដែរឬទេ[19]។

## IV. ការអនុវត្ត

១៩. សហចៅក្រមស៊ើបអង្កេត Harmon បានចេញដីកាកោះឲ្យបង្ហាញខ្លួនបឋម តែម្នាក់ឯង ដោយគ្មានហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង ឬ សេចក្តីសម្រេចផ្ទេរសិទ្ធិ។ ដីកាកោះហៅជនសង្ស័យត្រូវតែចេញដោយសហចៅក្រមស៊ើបអង្កេតដែលបំពេញកិច្ចរួមគ្នា។ មាត្រា

---

[18] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក./ក.ស.ច.ស. (អ.ប.ជ.៤១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធិ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដែលច្រានចោលសំណើសុំប្តឹងទៅអង្គបុរេជំនុំជម្រះតាមរយៈមោឃភាពការស៊ើបអង្កេតទាំងអស់ (D263/1) ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ១៦។

[19] *ដូចខាងលើ* កថាខណ្ឌ ១៨។

៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. តម្រូវឲ្យសហចៅក្រមស៊ើបអង្កេតសហការគ្នា និង ធ្វើការស៊ើបអង្កេតរួមគ្នា។

២០. វិធាន ១(២) ចែងថា "ជាពិសេសលើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និង ចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ"។ វិធាននេះបានផ្តល់គោលការណ៍ណែនាំពីការបកស្រាយវិធាន។ វិធាននេះ *មិនបាន* ផ្តល់យុត្តិកម្មសម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបោះបង់ចោលកាតព្វកិច្ចរបស់គាត់ក្នុងការបំពេញកិច្ចស៊ើបសួររួម ជាមួយសហចៅក្រមស៊ើបអង្កេតជាតិឡើយ។

២១. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះបានពន្យល់ (ពាក់ព័ន្ធទៅនឹងសហព្រះរាជអាជ្ញាបំពេញកិច្ចរួមគ្នា) ថា "បើសហព្រះរាជអាជ្ញាណាម្នាក់មិនបានផ្ទេរសិទ្ធិអំណាចនោះទេ គឺសហព្រះរាជអាជ្ញាម្នាក់ទៀតក៏មិនអាចបំពេញកិច្ចតែម្នាក់ឯងបាននោះដែរ"[20]។ ជាការពិត ចំណុចនេះក៏ត្រូវអនុវត្តផងដែរចំពោះសហចៅក្រមស៊ើបអង្កេត[21]។ មិនមានការចង្អុលបង្ហាញណាមួយដែលថា សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង បានផ្ទេរសិទ្ធិអំណាចរបស់គាត់ទៅឲ្យសហចៅក្រមស៊ើបអង្កេត Harmon ក្នុងការចុះហត្ថលេខាលើដីកាកោះឡើយ[22]។ ដីកាកោះក្នុងគោលបំណងធ្វើការចោទប្រកាន់ទៅលើជនសង្ស័យម្នាក់ មិនមែនជាប្រភេទនៃកិច្ច ដែលសហចៅក្រមស៊ើបអង្កេតអាចបំពេញតែម្នាក់ឯងបានឡើយ ដោយពិចារណាទៅលើកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត

---

[20] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង "សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និង សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ D20/4/4 កថាខណ្ឌ ៤។

[21] ដោយសារតែមាត្រាពាក់ព័ន្ធនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក. ដែលអាចអនុវត្តបានចំពោះសហព្រះរាជអាជ្ញា និង មាត្រាពាក់ព័ន្ធ ដែលអាចអនុវត្តបានចំពោះសហចៅក្រមស៊ើបអង្កេត ប្រើពាក្យពេចន៍សឹងតែដូចគ្នាបេះបិទ។ *សូមមើល* មាត្រា ៥(៤) និង ៦(៤) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។

[22] វិធាន ១៤(៤) ចែងថា សេចក្តីសម្រេចផ្ទេរភារកិច្ចត្រូវធ្វើឡើងរួមគ្នា៖ "វៀរលែងតែសកម្មភាពណា ដែលតម្រូវឲ្យអនុវត្តរួមគ្នាដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតអាចផ្ទេរភារកិច្ច ទៅឲ្យសហចៅក្រមស៊ើបអង្កេតណាមួយក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីរ តាមរយៈលិខិតរួមគ្នាជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យបំពេញកិច្ចតែម្នាក់ឯងបាន"។

អ.វ.ត.ក. ដែលតម្រូវឲ្យពួកគាត់សហការ និង បំពេញកិច្ចរួមគ្នា។ លក្ខណៈចម្រុះរបស់តុលាការនេះ ដែលបញ្ចូលផ្នែកជាតិ និង ផ្នែកអន្តរជាតិជាមួយគ្នា ក្នុងគោលបំណងឲ្យផ្នែកទាំងពីរបំពេញការងាររួមគ្នា តម្រូវឲ្យការសម្រេចប្រភេទនេះត្រូវបានធ្វើឡើងរួមគ្នា។

២២. សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវឲ្យបំពេញការងាររួមគ្នា ព្រោះវិធានផ្ទៃក្នុងតម្រូវឲ្យ "មានតម្រុយច្បាស់លាស់ និង ស៊ីសង្វាក់" ដើម្បីធ្វើការចោទប្រកាន់ទៅលើជនសង្ស័យ[23]។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតខ្វែងយោបល់គ្នាលើបញ្ហាថាតើ មានភស្តុតាងច្បាស់លាស់ និង ស៊ីសង្វាក់ដែរឬអត់នោះ ការខ្វែងយោបល់នេះបង្ហាញថា ភស្តុតាងនោះពិតជា *មិនមាន* ឡើយ មានន័យថា ចៅក្រមដែលប្រកបដោយហេតុផលត្រឹមត្រូវ យល់ឃើញផ្សេងគ្នាចំពោះការបកស្រាយទៅលើភស្តុតាង។ ក្នុងកាលៈទេសៈបែបនេះ ជាការមិនត្រឹមត្រូវទេ ដែលសហចៅក្រមស៊ើបអង្កេតមួយរូបចេញដីកាកោះ ហើយនឹងធ្វើការចោទប្រកាន់ទៅលើជនសង្ស័យដោយរូបគាត់តែម្នាក់ឯងនោះ។ ប្រសិនបើមានមន្ទិលសង្ស័យចំពោះបញ្ហាថាតើ ភស្តុតាងនោះច្បាស់លាស់ និង ស៊ីសង្វាក់ឬអត់នោះ រដ្ឋធម្មនុញ្ញកម្ពុជាតម្រូវថា មន្ទិលសង្ស័យបែបនេះត្រូវតែដោះស្រាយឲ្យបានជាប្រយោជន៍ដល់ខាងមេធាវីការពារក្តី[24]។

២៣. កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចែងថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនអាចមានការយល់ស្របគ្នាលើបញ្ហា ថាតើត្រូវបន្តដំណើរការស៊ើបអង្កេត ឬអត់នោះ ការស៊ើបអង្កេតត្រូវបន្ត រហូតដល់ពេលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនការខ្វែងយោបល់គ្នានេះទៅអង្គបុរេជំនុំជម្រះ ដើម្បីដោះស្រាយបញ្ហានេះដោយផ្អែកលើនីតិវិធី ដោះស្រាយជម្លោះ ដែលមានចែងក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[25]។

---

[23] វិធាន ៥៥(៤)។

[24] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ហើយកែសម្រួលដោយព្រះរាជក្រម ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ប្រកាសឲ្យប្រើវិសោធនកម្មមាត្រា ១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និងមាត្រាដទៃទៀតចាប់ពីជំពូក ៨ ដល់ជំពូក ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តដោយរដ្ឋសភា កាលពីថ្ងៃ ០៤ ខែ មីនា ឆ្នាំ ១៩៩៩។

[25] សូមកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេត Harmon បានបញ្ជាក់ថា ការខ្វែងយោបល់គ្នាក្នុងពេលបច្ចុប្បន្នរវាងរូបគាត់ជាមួយសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង មិនត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះឡើយ។ មេធាវីការពារក្តីមិនបានដឹងថាតើការខ្វែងយោបល់ទាំងនេះ សំដៅទៅលើ ការកោះហៅលោក មាស មុត ឬអត់ទេ។ សូមមើល លិខិតរបស់សហចៅក្រមស៊ើប

២៤. ការស៊ើបអង្កេតមួយអាចបន្ត ទោះបីជាជនសង្ស័យត្រូវបានកោះហៅ ឬ មិនបានកោះហៅក៏ដោយ។ ចំណុចនេះគឺផ្ទុយទៅនឹងស្ថានភាពដែលសហចៅក្រមស៊ើបអង្កេតមួយរូបយល់ថា *សាក្សី* ណាម្នាក់គួរត្រូវបានកោះហៅ។ ស្ថានភាពនេះបានកើតឡើងនៅក្នុងរឿងក្តី ០០២ នៅពេលដែលសហចៅក្រមស៊ើបអង្កេត Lemonde បានបំពេញកិច្ចតែម្នាក់ឯង ក្នុងការចេញដីកាកោះហៅសម្តេចព្រះវររាជបិតា ព្រមទាំងសាក្សីក្នុងជួររដ្ឋាភិបាលមួយចំនួន។ អង្គបុរេជំនុំជម្រះបានច្រានចោលទឡ្ហីករណ៍ដែលថា សកម្មភាពដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត Lemonde តែម្នាក់ឯង មិនមានសុពលភាព ព្រោះដីកាកោះមិនត្រូវបានចុះហត្ថលេខាដោយដៃគូរបស់គាត់ គឺសហចៅក្រមស៊ើបអង្កេតជាតិនោះ[26]។ ការកោះហៅសាក្សីទាក់ទងទៅនឹងការបន្តដំណើរការស៊ើបអង្កេត។ ប្រសិនបើសាក្សីម្នាក់មិនត្រូវបានកោះហៅ ការស៊ើបអង្កេតមិនអាចបន្តទៅមុខទៀតក្នុងការប្រមូលសក្ខីកម្មរបស់សាក្សីរូបនោះទេ។

២៥. ការកោះហៅជនសង្ស័យ *អាច* ទាក់ទងទៅនឹងបញ្ហាថាតើ ការស៊ើបអង្កេតអាចបន្ត ឬមិនបន្ត។ ជាឧទាហរណ៍ ប្រសិនបើសហចៅក្រមស៊ើបអង្កេតចង់សួរចម្លើយជនសង្ស័យ ដោយសារគាត់សង្ឃឹមថានឹងអាចទទួលបានព័ត៌មាន ដែលគាត់យល់ឃើញថាចាំបាច់សម្រាប់កិច្ចស៊ើបអង្កេត។ ប៉ុន្តែ លោក មាស មុត បានជម្រាបទៅសហចៅក្រមស៊ើបអង្កេតច្រើនដងរួចមកហើយថា គាត់មិនមានបំណងឆ្លើយតបទៅនឹងសំណួរណាមួយឡើយ ហើយគាត់ចង់ប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយ[27]។ សហចៅក្រមស៊ើបអង្កេត Harmon បានទទួលស្គាល់ការណ៍នេះ ហើយបានថ្លែងថា

---

អង្កេត Harmon ផ្ញើទៅមេធាវីការពារក្តី *សំណើសុំព័ត៌មានទាក់ទងនឹងកំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ និង ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៣* ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D82/3/2។

[26] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧ យោងទៅលើ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០ និង ៥១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស. លើសំណើសុំកោះហៅសាក្សី ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D314/1/8។

[27] ថ្មីជាងគេបង្អស់ លោក មាស មុត បានថ្លែងយ៉ាងដូច្នេះនៅក្នុងសេចក្តីជូនដំណឹងរបស់គាត់អំពីការមិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1.1។

នឹងមិនមានកិច្ចសម្ភាសន៍នៅឯការបង្ហាញខ្លួនបឋមឡើយ[28]ហេតុដូច្នេះ ការកោះហៅលោក មាស មុត អាចធ្វើឡើងតែក្នុងគោលបំណងចោទប្រកាន់គាត់តែប៉ុណ្ណោះ[29]។

២៦. ការកោះហៅជនសង្ស័យ ក្នុងគោលបំណងចោទប្រកាន់គាត់ *មិន* ទាក់ទងទៅនឹងបញ្ហាថាតើកិច្ចស៊ើបអង្កេតនឹងបន្តឬយ៉ាងណានោះឡើយ។ ការកោះហៅនេះគឺជាសកម្មភាពមួយដែលទាក់ទងនឹងបញ្ហាថាតើ *ការជំនុំជម្រះ* នឹងអាចមានដំណើរការឬក៏អត់។ កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មិនបានចែងអំពីស្ថានភាពបែបនេះទេ។ រដ្ឋធម្មនុញ្ញកម្ពុជាតម្រូវថា រាល់មន្ទិលសង្ស័យត្រូវដោះស្រាយឲ្យបានជាប្រយោជន៍ដល់លោក មាស មុត។ ហេតុដូច្នេះ ប្រសិនបើមានមន្ទិលសង្ស័យចំពោះថាតើ ពាក្យ "ការស៊ើបអង្កេត" ដែលមាននៅក្នុងមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មានន័យថាជា "ការជំនុំជម្រះ" ឬអត់នោះ អង្គបុរេជំនុំជម្រះនឹងត្រូវសម្រេចថា វាមិនមែនមានន័យបែបនេះឡើយ។ ទោះបីជានៅក្នុងរឿងក្តី ០០៤ អង្គបុរេជំនុំជម្រះបានលើកយោងទៅមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. នៅពេលសម្រេចថា ដីកាកោះអាចចេញដោយសហចៅក្រមស៊ើបអង្កេតតែមួយរូបក៏ដោយ[30] មាត្រាទាំងនេះមិនអាចអនុវត្តបានទៅលើស្ថានភាពបច្ចុប្បន្ននេះឡើយ ព្រោះមាត្រាទាំងនេះមិនបានដោះស្រាយការខ្វែងយោបល់គ្នា ដែលមិនទាក់ទងលើបញ្ហាថាតើកិច្ចស៊ើបអង្កេតនឹងបន្ត ឬអត់នោះឡើយ។

---

[28] ចម្លើយតបទៅនឹងសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ ("លិខិត") ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1/1 កថាខណ្ឌ ៦៖ "ដោយពិចារណាឃើញថា នឹងគ្មានកិច្ចសម្ភាសន៍កើតឡើងនៅក្នុងសវនាការ និង បានកត់សម្គាល់សេចក្តីសម្រេចចិត្តរបស់ជនសង្ស័យក្នុងការអនុវត្តសិទ្ធិនៅស្ងៀម យើងយល់ឃើញថា សម្រាប់គោលបំណងនៃការបង្ហាញខ្លួនបឋម វត្តមានរបស់សហមេធាវីតែម្នាក់ គឺគ្រប់គ្រាន់"។

[29] ជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានជូនដំណឹងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet ថា ពួកគេគឺជាជនសង្ស័យ ហើយត្រូវបានស៊ើបអង្កេត ដូច្នេះការកោះហៅ ដែលគ្រាន់តែដើម្បីជូនដំណឹងដល់ជនសង្ស័យអំពីការស៊ើបអង្កេត គឺជាឧបាយកល។ សូមមើល ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ D30។

[30] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក./ក.ស.ច.ស. (អ.ប.ជ. ០៩) សេចក្តីសម្រេចស្តីពី [redacted] សំណើបន្ទាន់ [redacted] ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/3 កថាខណ្ឌ ១៤ (នៅក្នុងសំណុំរឿង ០០៣ គឺ D117/1.2)។

២៧. វិធាន ៧២ គ្រប់ដណ្តប់លើការខ្វែងយោបល់គ្នា ក្នុងលក្ខណៈទូលំទូលាយជាង ការខ្វែងយោបល់គ្នាដែលបានត្រូវបានលើកឡើងដោយមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ យើងអាចយល់បានថា គួរតែមានវិធានលម្អិត សម្រាប់ពន្យល់ពីនីតិវិធីដែលត្រូវអនុវត្តក្នុងករណីមានការខ្វែងយោបល់គ្នា។ ក៏ប៉ុន្តែ វិធានផ្ទៃក្នុងត្រូវបានអនុម័តដើម្បី "ធ្វើការចងក្រងនូវនីតិវិធីជាធរមានរបស់កម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ... អនុម័តវិធានមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមាន ពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬ ការអនុវត្ត ឬ ក៏ប្រសិនបើមានបញ្ហាពាក់ព័ន្ធទាក់ទងនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិនៅក្នុងច្បាប់កម្ពុជាទៅនឹងនិយាមអន្តរជាតិ"[31]។ វិធានផ្ទៃក្នុងមិនមានមូលដ្ឋាននៅក្នុងច្បាប់ជាធរមានឡើយ នៅពេលដែលវិធានចែងហួសពីអ្វីដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង នីតិវិធីកម្ពុជា។ វិធាន ៧២ (៣) ធ្វើហួសពីសិទ្ធិអំណាចរបស់ខ្លួន នៅពេលដែលចែងថា សកម្មភាព ឬ សេចក្តីសម្រេច *ទាំងអស់* ដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នា នឹងត្រូវបានអនុវត្ត[32]។

២៨. វិធាន ៧២(៣) មិនស្របទៅនឹងមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឡើយ ហើយក៏មិនអាចត្រូវបានពឹងផ្អែក ដើម្បីអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតមួយរូបបំពេញកិច្ច ដោយខ្លួនគាត់ផ្ទាល់ក្នុងការកោះហៅជនសង្ស័យឡើយ។ កិច្ចព្រម

---

[31] បុព្វកថានៃវិធានផ្ទៃក្នុង។

[32] ជាឧទាហរណ៍មួយនៃភាពមិនស៊ីសង្វាក់ខាងក្នុងនៃវិធាននេះ វិធាន ៧២ ក៏មានភាពផ្ទុយគ្នាផងដែរទាក់ទងនឹងការចាប់ខ្លួន។ វាមិនច្បាស់ទេ ថាតើដីកាចាប់ខ្លួនដែលបានស្នើនឹងត្រូវបានអនុវត្ត ឬយ៉ាងណា (ដោយសារសេចក្តីសម្រេចសំដៅលើវិធាន ៧២(៣) ឬ ៧២(៤) ឬ ថាតើសច្ចធារណ៍សេរីភាព (សំដៅផងដែរលើវិធាន ៧២(៤) នឹងលុបលើសេចក្តីសម្រេច ហើយរារាំងមិនឲ្យមានការអនុវត្តសេចក្តីសម្រេច ឬយ៉ាងណា។ វាក៏មិនច្បាស់ផងដែរថា សច្ចធារណ៍សេរីភាពនឹងអនុវត្ត *ត្រឹមតែ* ក្នុងករណីដែលការខ្វែងយោបល់ត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ ឬយ៉ាងណា (ដោយសារសច្ចធារណ៍នេះត្រូវបានយោងតែនៅក្នុងវិធាន ៧២(៤) តែមិនមាននៅក្នុងវិធាន ៧២(៣))។ វិធាន ៧២ ក៏ផ្ទុយផងដែរពីមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលអនុញ្ញាតឲ្យបញ្ចប់ការស៊ើបអង្កេតនៅក្នុងស្ថានភាពមួយចំនួននៅក្នុងករណីដែលការខ្វែងយោបល់មិនត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ។ ឧទាហរណ៍ ប្រសិនបើសហចៅក្រមស៊ើបអង្កេតបង្គាប់ឲ្យបិទការស៊ើបអង្កេត ហើយប្រសិនបើ សហចៅក្រមស៊ើបអង្កេតផ្សេងទៀតមិនយល់ស្រប ប៉ុន្តែមិនបានបញ្ជូនរឿងនេះទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេល ៣០ ថ្ងៃ ពាក្យសុំនៅក្នុងវិធាន ៧២(៣) នឹងតម្រូវឲ្យដីកាបិទការស៊ើបអង្កេតត្រូវបានអនុវត្ត។

ព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នេះ តម្រូវថា សហចៅក្រមស៊ើបអង្កេតធ្វើការជាមួយគ្នា។ ដីកាកោះឲ្យបង្ហាញខ្លួនបឋម គឺរំលោភលើមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ហើយហេតុដូច្នេះគឺមានកំហុសនីតិវិធី។

២៩. កំហុសនីតិវិធីនេះដកហូតសិទ្ធិរបស់លោក មាស មុត ពីព្រោះសហចៅក្រមស៊ើបអង្កេត Harmon ចាត់ទុកថា លោក មាស មុត បានរំលោភបំពានដីកាដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់[33] ហើយបានថ្លែងថា គាត់នឹងពិចារណាវិធានការណ៍បន្ថែមទៀត ដើម្បីធានាឲ្យមានការបង្ហាញខ្លួនរបស់លោក មាស មុត[34]។ ជាការពិត នៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត Harmon បានចេញដីកាមួយទាក់ទងនឹងការឃុំខ្លួន និង ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដីកាទីមួយបែបនេះដែលត្រូវបានធ្វើនៅក្នុងរឿងក្តី ០០៣[35]។ លោក មាស មុត មិនអាចត្រូវបានបង្ខំឲ្យអនុវត្តតាមដីកាដែលមានកំហុសនីតិវិធី និង អសុពលភាពនោះទេ។ ដីកាកោះឲ្យបង្ហាញខ្លួនបឋមត្រូវតែ បានចាត់ទុកជាមោឃៈ។

## V. សេចក្តីសន្និដ្ឋាន

៣០. ដីកាកោះឲ្យបង្ហាញខ្លួនបឋមរបស់សហចៅក្រមស៊ើបអង្កេត Harmon គឺមានកំហុសនីតិវិធី ពីព្រោះដីកានេះត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេត Harmon តែម្នាក់ឯង។ កំហុសនីតិវិធីនេះរំលោភបំពានសិទ្ធិរបស់លោក មាស មុត ពីព្រោះសហចៅក្រមស៊ើបអង្កេត Harmon កំពុងពិចារណាវិធានការណ៍បង្ខិតបង្ខំឲ្យលោក មាស មុត អនុវត្តតាមដីកាដែលអសុពលភាព។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតត្រូវប្តឹងអង្គបុរេជំនុំជម្រះឲ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនបឋមនេះ។

---

[33] "ការមិនមក [បង្ហាញខ្លួន] នឹងជាការរំលោភបំពានដោយផ្ទាល់ទៅលើដីកាដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់"។ ចម្លើយតបទៅនឹងសេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ ("លិខិត") ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1/1 កថាខណ្ឌ ៥។

[34] *ដូចខាងលើ*។

[35] Zylab ចង្អុលបង្ហាញថា ដីកាសម្ងាត់បំផុតមួយត្រូវបានចេញដោយ ក.ស.ច.ស. នៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៤។ ដីកានេះមានលេខឯកសារ C1។ ឯកសារដែលមានលេខជាអក្សរ C ទាក់ទងនឹងការឃុំខ្លួន និង លក្ខខណ្ឌនៃការអនុញ្ញាតឲ្យនៅក្រៅឃុំ។ *សូមមើល* មាត្រា ១.៣ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. កែសម្រួលលើកទី ៨។

**អាស្រ័យ** ដូចបានជម្រាបជូនតាមសំអាងហេតុទាំងអស់ខាងលើ មេធាវីការពារក្ដីសូមគោរពស្នើសុំសហចៅក្រមស៊ើបអង្កេតមេត្តា **ប្ដឹង** អង្គបុរេជំនុំជម្រះឲ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនបឋមនេះ។

សូមលោកចៅក្រមទទួលយកសំណើនេះដោយក្ដីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៥** ខែ**ធ្នូ** ឆ្នាំ **២០១៤**

សហមេធាវីការពារក្ដីលោក មាស មុត

______________________ ______________________

អាង ឧត្ដម Michael G. KARNAVAS